មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

លេខ:...01713/13.../ម.ស.ម.ក/

លិខិតចំហ

ម.ស.ម.ក សម្តែងការព្រួយបារម្ភខ្លាំងចំពោះពាក្យសម្តីរើសអើង ដែលបានពោលឡើងដោយ គណបក្សសង្គ្រោះជាតិ

សូមគោរពជូនចំពោះថ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិ៖

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") សម្តែងនូវក្តីព្រួយបារម្ភចំពោះសុន្ទរកថាដែលបានធ្វើឡើងដោយថ្នាក់ដឹកនាំរបស់គណបក្សសង្គ្រោះជាតិ គឺឯកឧត្តម សម រង្ស៊ី ដែលជាពាក្យសម្តីបង្អាប់បង្អោន និងជាការរើសអើងប្រឆាំងនឹងស្ត្រី និងប្រជាពលរដ្ឋវៀតណាម ក្នុងអំឡុងការប្រមូលផ្តុំគ្នាមួយនៅខេត្តសៀមរាប កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៣។

តាមព័ត៌មានដែលបានចុះផ្សាយតាមកាសែត *ដីឥដ្ឋបូទាដេលី* កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣[1] ក្នុងអំឡុងនៃការប្រមូលផ្តុំនោះ ឯកឧត្តម សម រង្ស៊ី បានថ្លែងថា ជនអន្តោប្រវេសន៍វៀតណាមដោយបានហៅពួកគាត់ថា "ឃួន" ដែលពាក្យនេះ ជារឿយៗ ត្រូវបានគេចាត់ទុកថា ជាពាក្យសម្តីបង្អាប់បង្អោន។ បន្ទាប់ពីវឌ្ឍនភាពមួយចំនួន ក្នុងការកាត់បន្ថយនូវពាក្យសម្តីរើសអើងប្រឆាំងនឹងជនជាតិវៀតណាម នៅមុនការបោះឆ្នោតឆ្នាំ២០១៣ ម.ស.ម.ក ខកចិត្តដែល គណបក្សសង្គ្រោះជាតិ ប្រើពាក្យសម្តីនេះម្តងទៀត ដែលធ្វើឲ្យបះពាល់ដល់ជនជាតិវៀតណាម ប្រការនេះ ពិតជាអាចលើកទឹកចិត្តឲ្យមានការរើសអើងចំពោះជនជាតិវៀតណាម-សញ្ជាតិកម្ពុជា ក៏ដូចជាការរើសអើងលើជនជាតិវៀតណាមដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា។

ជាងនេះទៀតនោះ ម.ស.ម.ក មានការខកចិត្តចំពោះពាក្យសម្តីដែលថា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន "អន់ជាងស្ត្រី"។ ការអំពាវនាវឲ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចុះចេញពីតំណែង ដោយធ្វើឡើងបន្ទាប់ពីសុន្ទរកថារបស់លោក សម រង្ស៊ី ដែលមានខ្លឹមសារថា " *ខ្ញុំអំពាវនាវដល់លោក ហ៊ុន សែន ខ្ញុំសុំប្រាប់រឿងមួយ៖ កុំអន់ជាងស្ត្រី [.....] មាននាយករដ្ឋមន្ត្រីមួយនៅប្រទេសថៃ គឺលោកស្រី យីងឡាក់ ស៊ីណាវ៉ាត្រា។ សូមទះដៃសារទរចំពោះលោកស្រី យីងឡាក់ស៊ីណាវ៉ាត្រា ប្រជាជនថៃតវ៉ាទាមទារឲ្យលោកស្រីចុះចេញពីតំណែង ហើយលោកស្រីបានព្រមធ្វើការបោះឆ្នោតឡើងវិញ*[....] ហេតុអ្វីបានលោក ហ៊ុន សែន អន់ជាងស្ត្រីម្លេះ? អ្នកគាំទ្រគណបក្សសង្គ្រោះជាតិ បន្ទាប់មកបានបន្ទរសម្តីតាមឯកឧត្តម សម រង្ស៊ី ដោយស្រែកថា "*ហ៊ុន សែន អន់ជាងស្ត្រី!*"

---

[1] អេឡិច វីលៀមិន និង ឃួន ណានិ "នៅខេត្តសៀមរាប លោក សម រង្ស៊ី អំពាវនាវម្តងទៀតឲ្យលោក ហ៊ុន សែន ចុះចេញពីតំណែង" (ខែធ្នូ ឆ្នាំ២០១៣)។

ប្រសិនបើមានការថ្លែងពាក្យសម្តីបែបនោះពិតមែន នេះមានន័យថា ស្ត្រីមានសមត្ថភាពចាញ់បុរសដែលនេះជាការពុំអាចទទួលយកបាន។ ប្រការនេះបង្កឲ្យមានអសមភាពយេនឌ័រ និងការបង្ខូចនូវទំនៀមទម្លាប់ផ្នែកយេនឌ័រ និងជាការធ្វើឲ្យប៉ះពាល់ដល់ការអភិវឌ្ឍន៍ប្រកបដោយសមភាពនៅកម្ពុជា។ បន្ទាប់ពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅឆ្នាំនេះ បានឃើញជាចម្បងថា មានការធ្លាក់ចុះនូវភាពជាតំណាងស្ត្រីនៅក្នុងរដ្ឋសភានៅក្នុងរយៈពេល២០ឆ្នាំមកនេះ ដែលនេះ ជាពេលវេលាដ៏សំខាន់សម្រាប់លើកទឹកចិត្តឲ្យមានសមភាពយេនឌ័រនៅក្នុងវិស័យនយោបាយ និងនៅគ្រប់ផ្នែកនៃសង្គម។

ម្យ៉ាងវិញទៀត សម្តីដែលបានថ្លែងឡើងនោះ គឺផ្ទុយទៅនឹងសេចក្តីថ្លែងការណ៍ដែលគណបក្សសង្គ្រោះជាតិបានចេញផ្សាយកាលពីថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៣ ដែលបានបញ្ជាក់ពីគោលជំហររបស់គណបក្សស្តីពីការបោះឆ្នោត លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ ក្នុងខ្លឹមសារសេចក្តីថ្លែងការណ៍នោះ បានលើកឡើងថា គណបក្សសង្គ្រោះជាតិ "ប្រឆាំងនឹងអំពើហិង្សា ការប្រកាន់ពូជសាសន៍ ការស្អប់ខ្ពើម និងការរើសអើង"។ សម្តីទាំងនេះ បានធ្វើឡើងចំនឹងថ្ងៃប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ និងត្រូវចំថ្ងៃលើកខួបលើកទី ៦៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលសេចក្តីប្រកាសនេះ លើកតម្កើងនូវសិទ្ធិមនុស្សជាសកល ដោយអនុវត្តស្មើភាពគ្នាចំពោះមនុស្សទូទៅ និងជាការប្រឆាំងទៅនឹងការរើសអើងនានា។

ដោយយោងលើព័ត៌មានខាងលើ យើងខ្ញុំស្នើសុំដោយក្តីគោរពរាប់អានថា គណបក្សសង្គ្រោះជាតិធ្វើការបញ្ជាក់ពីគោលជំហររបស់ខ្លួន ហើយប្រសិនបើ ការថ្លែងខាងលើនោះបានធ្វើឡើងមែន គួរណាស់តែសូមធ្វើការអភ័យទោសជាសាធារណៈ ចំពោះការដែលបានពោលពាក្យសម្តីដែលមានចរិតលក្ខណៈរើសអើង។ យើងខ្ញុំសូមជំរុញឲ្យគ្រប់សមាជិកគណបក្សសង្គ្រោះជាតិទាំងអស់ អនុវត្តតាមគោលការណ៍ នៅពេលលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍នាពេលអនាគត ដើម្បីជួយលុបបំបាត់នូវការរើសអើងនៅកម្ពុជា។

សូមជ្នាក់ដឹកនាំគណបក្សសង្គ្រោះជាតិ ទទួលនូវគោរវៈ និងការរាប់អានដ៏ស្មោះត្រង់អំពីយើងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣

ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

អ៊ូ ទីរៈ